ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៩ លេខ ០៣

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាពការងារ

ECOSOCC

កសវ




Work Activities

ប្រចាំខែមីនា ឆ្នាំ២០១៦



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត | ១ |
| ២- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែមីនា ឆ្នាំ២០១៦ | ៣ |
| ៣- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១១ |

## សេចក្តីព្រាងច្បាប់ស្តីពី

# ការគ្រប់គ្រងឧស្សាហកម្មភាពយន្ត

កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំ ជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌(ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋ មន្ត្រី និងតំណាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។



ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត ក្នុងគោលបំណងគ្រប់គ្រង អភិវឌ្ឍ និងធានានូវការត្រួតពិនិត្យវិស័យភាពយន្តប្រកបដោយនិរន្តភាព ដើម្បីចូលរួមចំណែកដ៏សំខាន់ក្នុងការជំរុញសេដ្ឋកិច្ចសង្គម ព្រមទាំងរក្សាការពារលើកតម្កើន និងអភិវឌ្ឍវប្បធម៌ជាតិ និងមានគោលដៅ គ្រប់គ្រងការផលិតភាពយន្តក្នុងស្រុក គ្រប់គ្រងការផលិតភាពយន្តរបស់បរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា គ្រប់គ្រងការធ្វើអាជីវកម្ម សេវាកម្មស្នាដៃភាពយន្ត គ្រប់គ្រងការផ្សព្វផ្សាយស្នាដៃភាពយន្ត បង្កើតនិងគ្រប់គ្រងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈភាពយន្ត លើកទឹកចិត្តដល់ការបង្កើតស្នាដៃភាពយន្តថ្មី និងត្រួតពិនិត្យនិងបង្ក្រាបបទល្មើសឧស្សាហកម្មភាពយន្ត និងមានវិសាលភាពអនុវត្តទៅលើគ្រប់សកម្មភាពទាំងអស់នៃឧស្សាហកម្មភាពយន្តនៅព្រះរាជាណាចក្រកម្ពុជា។

សូមរំឭកថា កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤ អង្គប្រជុំជំនាញបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រី បានពិនិត្យពិភាក្សាលើសេចក្តីកែសម្រួលអនុក្រឹត្យលេខ៦៣ អនក្រ.បក ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្តវីដេអូ ទៅជាសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត។ ក្រោយពីបានពិភាក្សាគ្នាយ៉ាងផុលផុស អង្គប្រជុំជំនាញបច្ចេកទេសបានឯកភាពលើសេចក្តីព្រាងអនុក្រឹត្យនេះ ចាប់ពីជំពូកទី១ ដល់

ជំពូកទី៤។ ដោយឡែកចំពោះជំពូកទី៥ ស្តីពីការត្រួតពិនិត្យ និងការដោះស្រាយវិវាទផ្នែកភាពយន្ត និងជំពូកទី៦ ស្តីពីទោសប្បញ្ញត្តិ អង្គប្រជុំបានសម្រេចប្រគល់សេចក្តីព្រាងនេះមកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈវិញ ដើម្បីធ្វើការកែសម្រួល និងពិគ្រោះយោបល់ជាមួយក្រសួងយុត្តិធម៌។

មន្ត្រីជំនាញរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានប្រជុំពិភាក្សាជាមួយមន្ត្រីតំណាងក្រសួងយុត្តិធម៌ជាច្រើនលើក ហើយជាចុងក្រោយ នាថ្ងៃទី១ ខែតុលា ឆ្នាំ២០១៥ តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានជួបប្រជុំជាមួយលោកស្រី **និល ឡើលីព** ប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងយុត្តិធម៌ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

-ចំពោះករណីបង្កើតគណៈកម្មការអន្តរក្រសួងត្រួតពិនិត្យបទល្មើស និងដោះស្រាយវិវាទផ្នែកភាពយន្ត តំណាងក្រសួងយុត្តិធម៌បញ្ជាក់ថា ជាគោលការណ៍ រាជរដ្ឋាភិបាលមិនចង់បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីបំពេញតួនាទីជំនួសស្ថាប័នសាមីទេ។ ក្រសួងសាមីអាចធ្វើការនេះ ដោយផ្ទាល់ជាមួយស្ថាប័នមានសមត្ថកិច្ច(តុលាការ)។

-តំណាងក្រសួងយុត្តិធម៌ បានធ្វើការសម្រួលចំណុចជាច្រើនក្នុងជំពូកទី៦ ស្តីពីទោសប្បញ្ញត្តិ និងបានបន្ថែមមាត្រាថ្មីមួយ ដែលចែងពីបែបបទនៃបង្កាន់ដៃផាកពិន័យ និងការគ្រប់គ្រងចំណូលដែលបានមកពីការផាកពិន័យ[១]។



ក្រោយពីស្តាប់របាយការណ៍ពីតំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមីនាឆ្នាំ២០១៦*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌កម្ពុជា **ប្រចាំខែមីនា ឆ្នាំ២០១៦**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ECOSOCC) នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែមីនាឆ្នាំ២០១៦សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថយចុះ០,២%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២%ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +១០,៥% | សាច់គោ: | +១០,៨% |
| ភោជនីយដ្ឋាន: | +៥,៨% | ត្រីស្រស់: | +៩,៤% |
| ម្ហូបអាហារ: | +៤,៧% | សាច់មាន់: | +៥,៥% |
| សំលៀកបំពាក់ និងស្បែកជើង : | +៤% | សាច់ជ្រូក: | +៤,២% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់ : | +៣,៦% | ផ្លែឈើ: | +៣,៩% |
| ការកំសាន្តនិងវប្បធម៌ : | +៣% | បន្លែ: | +២,៤% |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៤–២០១៦

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា P | ឧសភា P | មិថុនា P | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,១% | ២,០% | ២,០% | | | | | | | |
| | មុន | -០,២% | ០,៤% | -០,២% | ០,៧% | ០% | ០,២% | | | | | | | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | ០% | -០,២% | ០,២% | |
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ២,៥% | ៤,០% |
| | មុន | ០,២% | ០ | ០,៥% | ០,៥% | ០,៣% | ០,៥% | ០,៤% | ០,៣% | ០,២% | -០,៤% | -០,៨% | ០,៧% | |

**P:** តួលេខខែមេសា ឧសភា និងមិថុនាឆ្នាំ២០១៦ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់







តារាង១.៣ .អត្រាប្តូរប្រាក់

| *ប្រភេទ* | មីនា២០១៦ | កុម្ភៈ២០១៦ | មីនា២០១៥ | *ប្រភេទ* | មីនា២០១៦ | កុម្ភៈ២០១៦ | មីនា២០១៥ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០០៦៛/១$ | ៤០០៨៛/១$ | ៤០១០៛/១$ | **បាត/ដុល្លារ** | ៣៥,២៣បាត/១$ | ៣៥,៧៣បាត/១$ | ៣២,៥៤បាត/១$ |
| **៛/បាត** | ១១៤៛/១បាត | ១១២៛/១បាត | ១២៣៛/១បាត | **ដុង/ដុល្លារ** | ២២២២៨ដុង/១$ | ២២២៩៣ដុង/១$ | ២១៥១៥ដុង/១$ |
| **៛/ដុង** | ០,១៨០៛/១ដុង | ០,១៨០៛/១ដុង | ០,១៨៦៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែមីនាឆ្នាំ២០១៦ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៦២០,៥ប៊ីលានរៀល( *មធ្យមប្រចាំខែ ១០៣% នៃផែនការ*) ក្នុងនោះ ចំណូលចរន្តចំនួន១៦១១,១ប៊ីលានរៀល( *មធ្យមប្រចាំខែ ១០៥% នៃផែនការ*) និងចំណូលមូលធនមាន៩,៤ប៊ីលានរៀល (តាមតួលេខ រតនាគារជាតិ)។

➤បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង៥៤,៣%និងកើនឡើង៣៥,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➤នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១៤៩៦,៥ប៊ីលានរៀល កើនឡើង៥៦,៣%ធៀបនឹងខែមុន និងកើនឡើង៤៣,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៤–២០១៦
(ប៊ីលានរៀល)




✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១១៤,៦ប៊ីលានរៀល កើនឡើង៣៦,៦%ធៀបនឹងខែមុន ប៉ុន្តែថយចុះ១៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +២៥,៨% | (+៣៨,៨%) | ➢ នេសាទ:+៣៥,៦% | (-៤៦,១%) |
| (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | | ➢វុឌ្ឍប្រមាញ់: +៣៧២,៨% | |
| ➢ *ចំណូលពន្ធដារ:* +១៣២% | (+៣១,២%) | ➢សម្បទានរ៉ែ: -២៩,១% | (-២២,៤%) |
| (អគ្គនាយកដ្ឋានពន្ធដារ) | | ➢ អាកាសចរណ៍ស៊ីវិល: -៦៩% | (+១៧៨%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: +កើនគំហុគ | (-៥១,៨%) |
| ✧ កាស៊ីណូ : +២៣,១% | (+១៤,៧%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍: +៧៤៣,១% | (+៧៦៥,១%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +១៦៩,៦% | (-៤៤%) | ➢អាករស្ពានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): +២២,៨% | (-៣៣,៦%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ៦៤៦ប៊ីលានរៀល(*មធ្យមប្រចាំខែ ៥៧% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន៥៣៧,៩ ប៊ីលានរៀល (*មធ្យមប្រចាំខែ ៥៦% នៃផែនការ*) និងចំណាយមូលធនមានចំនួន១០៨,១ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិថយចុះ០,៨%ធៀបនឹងខែមុនប៉ុន្តែកើនឡើង២៥,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង ១៤,៥%ធៀបនឹងខែមុននិងកើនឡើង២៦,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះ មានអតិរេកចំនួន **៩៧៤,៦**ប៊ីលានរៀល (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៤–២០១៦
(ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមីនាឆ្នាំ២០១៦មានលក្ខណៈដូចខាងក្រោម:

➢ រូបិយវត្ថុ $M_2$ មានចំនួន៥០៨៩១ប៊ីលានរៀល កើនឡើង១,៧%ធៀបនឹងខែមុន និងកើនឡើង ១៦,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង $M_2$** ក្នុងខែនេះ ជារួម បណ្តាលមកពីការកើនឡើងនៃប្រាក់បញ្ញើជារូបិយបណ្ណ២,៦%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែមីនាឆ្នាំ២០១៦



➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៥,៩% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,១% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៦

| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៦,៨% | ១៦,៦% | ១៥,៩% | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១២,២% | ១២,១% | ១១,៩% | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែមីនា២០១៦: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៥៣៨៧លានដុល្លារ កើនឡើង៥,១%ធៀបនឹងខែមុន និងកើន ២១,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១៥៦៩៨ ប៊ីលានរៀលថយចុះ០,១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៨,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *មីនា២០១៦* | *កុម្ភៈ២០១៦* | *មីនា២០១៥* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) ក្នុងនោះ ជារៀល | ៥០៨៧៥ | ៥០៤៨៩ | ៤០៤១៦<br>៥១៥ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១២៧៣៧ | ៩១៥១ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៥៣% | ៦,៥៣% | ៦,៧៩% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,៣៥% | ១៦,៣៥% | ១៦,១៧% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៥% | ៤,៤៥% | ៤,៣% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៤៥% | ១១,៤៥% | ១១,៣៥% |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែមីនាឆ្នាំ២០១៦ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៤១,៣ពាន់តោនថយចុះ១៤%ធៀបនឹងខែមុន និងថយចុះ២២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ **រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៥៥៥,៤៨GWHមានការកើនឡើង១០%ធៀបនឹងខែមុន និងកើនឡើង១៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៦៩,០៦GWH មានការកើនឡើង៧៤%ធៀបនឹងខែមុន និងកើនឡើង៥៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន២៤៩,៤៩GWHមានការថយចុះ៨%ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ **ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៥៣០,៣លានដុល្លារមានការកើនឡើង៥%ធៀបនឹងខែមុន និងកើនឡើង៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន —មីនា២០១៦ | ចំនួន—កុម្ភៈ២០១៦ | ចំនួន—មីនា២០១៥ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១៤ | ១២ | ២១ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៤៩០ | ១៤៧៦ | ១៣៣៦ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម(បើកថ្មី) | — | — | — |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | — | — | — |

➢ **សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ២២៣៣,៨ពាន់ម២កើនឡើង១៥៦%ធៀបនឹងខែមុន និងកើនឡើង១០៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៧៤៧,៨លានដុល្លារកើនឡើង៤៧%ធៀបនឹងខែមុន និងកើនឡើង១១៤%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម២ —មីនា២០១៦ | ពាន់ម២ —កុម្ភៈ២០១៦ | ពាន់ម២ —មីនា២០១៥ |
|---|---|---|---|
| ▪ លំនៅឋាន | ៣៣២,៦ | ៦១៣,៨ | ៩១០,៤ |
| ▪ ឧស្សាហកម្ម | ៨៧,២ | ១៤២,៥ | ១២១ |
| ▪ពាណិជ្ជកម្ម | ១៧៨៩,៦ | ១០៣,១ | ២៧,៩ |
| ▪ ទេសចរណ៍ | ២២,១ | ៤,៥ | ៨,៧ |
| ▪ផ្សេងៗ | ១,៦ | ១,៣ | ៥ |
| អនុញ្ញាតសរុប | ២២៣៣,៨ | ៨៧២,១ | ១០៨១,៥ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺពាណិជ្ជកម្ម៨០% នៃផ្ទៃក្រឡាសរុប។

➢ **ការងារ**

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់—មីនា២០១៦ | នាក់—កុម្ភៈ២០១៦ | នាក់—មីនា២០១៥ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបបនិងការងារ ) | ១០៣៧ | ៤៤១ | ៧៣៥ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៨៥០២ | ១៣៥៨៧ | ៥៨៤៦ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៦៥៤៨ | ១១២៣៤ | ៤០២៣ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៩៥៤ | ២៣៥៣ | ១៨២៣ |

### ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | មីនា២០១៦ | កុម្ភៈ២០១៦ | មីនា២០១៥ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៤០,១ | ៧៩៨,៩ | ២៨២៥,៣ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ៣៨,៣ | ២៧៨,២ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៤០<br>(៥) | ៤៧,៧<br>(១,៦) | ៧៨,៧<br>(២៥,២) |
| វិស័យទេសចរណ៍ | ០ | ៥៧៣ | ២៧,២ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ១៤០ | ២៤៤១,២ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៩ | ២០ | ២៨ |
| បង្កើតការងារ (ពាន់នាក់) | ១៦,១ | ២២,១ | ៣១,៨ |

### ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន —មីនា២០១៦ | ចំនួន—កុម្ភៈ២០១៦ | ចំនួន—មីនា២០១៥ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | | | ៣៣០ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | | | ២ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៩០៥ | ៧៩៦ | ១១៣ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៧៦៤,៩ពាន់តោនកើនឡើង៩%ធៀបនឹងខែមុន ប៉ុន្តែថយចុះ៩%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះៈ

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញៈ+១% | (+៨%) | ▪ កំពង់ផែស្រែអំបិល និងកោះកុងៈ-២០% | (-២២%) |
| ▪ កំពង់ផែកំពង់សោមៈ+២៥% | (-០%) | ▪ កំពង់ផែឧកញ៉ាម៉ុងៈ -៥,៦% | (-៥៤%) |

### ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៤,៧ | ១៥% | ១៧% |
| ក្នុងនោះទទួល | ២,២ | ១% | ៧% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១១៨,៨ | -៦% | -២% |
| ក្នុងនោះទទួល | ៥០,៨ | ៥% | ១៣% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៨២២,៦ | -១% | -២៨% |
| ក្នុងនោះហៅចូល | ៧១០,៧ | -១៤% | -៣៣% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១១២២៥,៥ | -៦% | -៤% |
| ក្នុងនោះហៅចូល | ១១១៧០,៥ | -៦% | -៣% |

### ➢ ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៥៥,១ | ១៥១% | ២០៣% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៣៩,២ | -១៨% | -៣% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៥៤២ | -៨% | ៦% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១០៣,៩ | -១០% | ១៩% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤២៧,៩ | -៥% | ៣% |
| ✓ តាមផ្លូវអាកាស | ២៤៤,៦ | -៩% | ៧% |
| ✓ តាមផ្លូវគោក និងទឹក | ១៨៣,៤ | ១% | -២% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែមីនាមានចំនួន ៤៣៩៤ប៊ីលានរៀល (ស្មើនឹង១០៩៨,៥ លានដុល្លារ ស.រ.អា.)កើនឡើង៨,៩%ធៀបនឹងខែមុននិងកើនឡើង១០,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆□ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -២៥,៨% | -១០,៥% | រថយន្តសរុប (ប៊ី.ល.រ) | +៤០,៥% | +៧១,៣% |
| ប្រេងម៉ាស៊ូត | -១១,៤% | -១១,៨% | រថយន្តសរុប (គ្រឿង) | +២៧,៦% | +៦៧,៩% |
| ឧស្ម័ន | +១០,៩% | +៧៦,២% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -២,៣% | -២៥,៣% |
| អគ្គិសនីនាំចូល | +២៨% | +៣% | ម៉ូតូ (គ្រឿង) | +២១,៧% | +៣៧,៦% |
| ដែកសំណង់ | +២៦,១% | +៤៤% | អង្ករ | +៧២,៦% | -៥១,៧% |
| ស៊ីម៉ង់ត៍ | +២៥% | -២០,៤% | ផ្លែឈើនិងបន្លែ | +២១,៨% | -៨,៣% |
| គ្រឿងអេឡិចត្រូនិក | +៤៥,៣% | +៩៧% | ជីនិងថ្នាំកសិកម្ម | +៧៨,៤% | +៣១,៧% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +២៣,៨% | +២០,៣% |

➡ **ការនាំចេញ** ខែមីនាឆ្នាំ២០១៦ មានចំនួន**៣០២០,៨**ប៊ីលានរៀល ស្មើនឹង**៧៥៥,២**លានដុល្លារ ស.រ.អា. (**៦៨,៧**% នៃការនាំចូល)ថយចុះ១%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១២,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៩៨,១% | -៩៥,១% | ផលិតផលនេសាទ | +៦១% | +១៤៩,៤% |
| វាយនភណ្ឌនិងស្បែកជើង | -៧,៣% | +១៥,៤% | កៅស៊ូ | +៧២,៧% | +២,៤% |
| អង្ករ | +១៩,៤% | -២៣,៧% | | | |




➡ក្នុងខែមីនានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ១៣៧៣,១ប៊ីលានរៀល ស្មើនឹង ៣៤៣,៣លានដុល្លារ ស.រ.អា.។

## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមីនាឆ្នាំ២០១៦នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់គោស្រស់ | +០,៤% | +១០,៨% | — |
| ២ | ថ្លៃត្រីស្រស់ | +០,៥% | +៩,៤% | — |
| ៣ | ទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក | -៩៥% | -៩៩% | — |

## ៧) សេចក្តីសន្និដ្ឋាន

១) គ្រួសារមួយចំនួនធំនៅជនបទ ជាប់ជំពាក់បំណុល និងសងការប្រាក់ដែលមានអត្រាខ្ពស់ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអ្នកឲ្យខ្ចីផ្សេងទៀត។ បញ្ហាអវិជ្ជមានបានកើតឡើងដោយសារមានគ្រួសាខ្លះប្រឈមនឹងការរឹបអូសទ្រព្យសម្បត្តិដាក់បញ្ចាំនៅពេលដែលពួកគេពុំមានលទ្ធភាពសងបំណុល ដោយសារការប្រើប្រាស់កម្ចីខុសទិសដៅឬក៏អាជីវកម្មមានការខាតបង់។

ដើម្បីដោះស្រាយបញ្ហានេះ គួរតែមានវិធានការមួយចំនួនរួមមាន ការលើកកម្ពស់ការអនុវត្តវិធាននៃការផ្តល់ឥណទានពីសំណាក់អ្នកឲ្យខ្ចី ដោយផ្អែកលើលទ្ធភាពសងរបស់អ្នកខ្ចី និងជៀសវាងការផ្តល់កម្ចីធ្វើឲ្យអ្នកខ្ចីជាប់បំណុលហួសហេតុ។

២) សំណង់លំនៅឋាន ដូចជាផ្ទះល្វែង បុរី ខុនដូរ កំពុងប្រព្រឹត្តយ៉ាងសកម្ម ។ អង្គប្រជុំបានសង្កត់ធ្ងន់លើភាពចាំបាច់ នៃការយកចិត្តទុកដាក់លើគុណភាពសំណង់ស្របតាមបទដ្ឋានបច្ចេកទេស ប្រព័ន្ធលូក្រោមដី និងវិធានការបង្ការអគ្គីភ័យ ។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៦

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៣/១៦<br>ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទវេទិកាជាតិយុវជន និងទីក្រុងស្អាតលើកទី១ និងពិធីអបអរសាទរទិវាជាតិទីក្រុងស្អាតលើកទី៤ ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| ២ | ០១/០៣/១៦<br>ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ រយៈពេល ១០ឆ្នាំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៣ | ០២/០៣/១៦<br>ម៉ោង១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធានការហាម ការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ ឬកន្លែងសាធារណៈ។<br>៣-សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ "អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ១៩៨២"។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៣/០៣/១៦<br>ម៉ោង១៥:៣០នាទី | អមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉េង ប៉ាត់** នៅគេហដ្ឋាននៃសព។ |
| ៥ | ០៤/០៣/១៦<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធានការហាម ការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ ឬកន្លែងសាធារណៈ។<br>៣-សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ "អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ១៩៨២"។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៦ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៦ | ០៦/០៣/១៦ ម៉ោង១៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីរៀបចំទទួលជប់លៀងស្វាគមន៍ជូនគណៈប្រតិភូចិន ដឹកនាំដោយលោក Wang Yanzhi ប្រធាននៃមូលនិធិផ្លូវសូត្រចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅភូមិគ្រឹះរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ |
| ៧ | ០៨/០៣/១៦ ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរខួបលើកទី១០៥ ទិវាអន្តរជាតិនារី ៨ មីនា ២០១៦ ក្រោមប្រធានបទ "វិនិយោគលើសមភាពយេនឌ័រ ដើម្បីកិច្ចអភិវឌ្ឍប្រកបដោយចីរភាព" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៨ | ០៩/០៣/១៦ ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវកំណាត់ផ្លូវលេខ 1TK1 និងបើការដ្ឋានសាងសង់កំណាត់ផ្លូវចំនួន ០២ខ្សែ ស្ថិតនៅក្នុងស្រុកអង្គរបូរី ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅស្រុកអង្គរបូរី ខេត្តតាកែវ។ |
| ៩ | ១០/០៣/១៦ ម៉ោង០៨:០០នាទី | ចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបការងារសុខាភិបាលប្រចាំឆ្នាំ២០១៥ លើកទី៣៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅសណ្ឋាគារសូហ្វីតែល។ |
| ១០ | ១០/០៣/១៦ ម៉ោង១៥:៣០នាទី | អញ្ជើញពិនិត្យមើលការដ្ឋានស្ថានីយ៍អ្នកដំណើរពង្រីកថ្មីព្រលានយន្តហោះអន្តរជាតិភ្នំពេញ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១១ | ១១/០៣/១៦ ម៉ោង០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងការអញ្ជើញត្រួតពិនិត្យមើលការដ្ឋានស្ថានីយ៍អ្នកដំណើរពង្រីកថ្មីព្រលានយន្តហោះអន្តរជាតិភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១២ | ១៤/០៣/១៦ ម៉ោង០៧:៤៥នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសបើកសន្និសីទជាតិស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៦ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៣ | **១៥/០៣/១៦ ម៉ោង១៨:១៥នាទី** | ចូលរួមពិធីជប់លៀងក្នុងឱកាសប្រារព្ធខួបលើកទី២០ នៃអាកាសយានដ្ឋានកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសូហ្វីតែល។ |
| ១៤ | **១៦/០៣/១៦ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ថានីយ៍អ្នកដំណើរថ្មី នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ |
| ១៥ | **១៦/០៣/១៦ ម៉ោង១៥:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្ដីពីគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **១៧/០៣/១៦ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតសាកលវិទ្យាល័យន័រតុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១៧ | **១៨/០៣/១៦ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ជាតិ។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្ដីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។<br>៣-បញ្ហាផ្សេងៗ ។<br>នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៦ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៨ | **២១/០៣/១៦ ម៉ោង០៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសដាក់ឲ្យអនុវត្តដំណាក់កាលទី៣ និងកិច្ចប្រជុំត្រួតពិនិត្យវាយតម្លៃវឌ្ឍនភាពប្រចាំឆ្នាំ២០១៥ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែល។ |
| ១៩ | **២១/០៣/១៦ ម៉ោង១៣:០០នាទី** | ចូលរួមពិសារភោជនាហារពេលថ្ងៃត្រង់ជាមួយ លោក MENANTEAU CEO ក្រុមហ៊ុន SCA និងលោក CEO ថ្មី នៅសណ្ឋាគារឡឺរ៉ូយ៉ាល់។ |
| ២០ | **២១/០៣/១៦ ម៉ោង១៩:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីពិសារភោជនាហារពេលល្ងាចជាមួយ ឯកឧត្តម ឯកអគ្គរដ្ឋទូតបារាំង នៅស្ថានទូតបារាំង។ |
| ២១ | **២២/០៣/១៦ ម៉ោង០៩:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ម៉ិច សុខា** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២២ | **២២/០៣/១៦ ម៉ោង១៦:០០នាទី** | បន្តជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ម៉ិច សុខា** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | **២៣/០៣/១៦ ម៉ោង១០:០០នាទី** | ចូលរួមជួបពិភាក្សាការងារជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅគេហដ្ឋាន ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ |
| ២៤ | **២៥/០៣/១៦ ម៉ោង១០:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីផ្តល់ប្រាក់ពានរង្វាន់ជ័យលាភីបន្ថែមជូនដល់កីឡាករ កីឡាការនី និងគ្រូបង្វឹក នៃសហព័ន្ធកីឡាប៊ូល និងប៉េតង់កម្ពុជា ដែលបានចូលរួមប្រកួតកីឡាប៊ូល និងប៉េតង់ជើងឯកអាស៊ីលើកទី១៩ នៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៥ | **២៥/០៣/១៦ ម៉ោង១៦:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៦ | **២៨/០៣/១៦ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៧ | **២៩/០៣/១៦ ម៉ោង០៨:៣០នាទី** | តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីបើកសន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៤-២០១៥ និងលើកទិសដៅសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៦ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ២៨ | ២៩/០៣/១៦<br>ម៉ោង១៥:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់ពានរង្វាន់សន្តិភាព និងការអភិវឌ្ឍ ជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ពីសហព័ន្ធប្រព័ន្ធផ្សព្វផ្សាយអាស៊ាន(THE UNION MEDIA OF ASEAN) នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២៩ | ៣០/០៣/១៦<br>ម៉ោង១៥:៣០នាទី | ដឹកនាំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួលនិងសហការជាមួយភាគីចិន ចុះត្រួតពិនិត្យវាយតម្លៃអគារថ្មីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីត្រៀមប្រគល់-ទទួលនៅអគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣០ | ៣១/០៣/១៦<br>ម៉ោង១៥:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្ត អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំវក អដ្ឋស័ក ព.ស ២៥៦០ គ.ស ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទូរស័ព្ទលេខៈ ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខៈ ០២៣ ២១១ ៩៤៣

E-mail: veasna@live.in